## តើកម្មវិធី CHDP មានផ្តល់អ្វីអោយ ?

### ការមកពិនិត្យមើលខ្លួនប្រាណជាប្រចាំ :

- ♥ មកពិនិត្យមើលនៃការកើនកំពស់ និងធំធាត់
- ♥ ចាក់ថ្នាំដែលតម្រូវឲ្យចាក់ទាំងអស់
- ♥ ថតពិនិត្យមើលធ្មេញ
- ♥ ថតពិនិត្យមើលភ្នែក
- ♥ ថតពិនិត្យមើលត្រចៀក (ស្តាប់)
- ♥ ពិនិត្យមើលម្ហូបអាហារបរិភោគប្រចាំ
- ♥ ការអប់រំសុខភាព
- ♥ ការអប់រំពីថ្នាំជក់
- ♥ ធ្វើតេសន៏មើលរោគខ្វះឈាមក្រហម, ជាតិសំណរក្នុងឈាម, ទឹកនោម, រោគរបេង ហើយនិង រោគាផ្សេងៗទៀត
- ♥ ការបញ្ជូនរបស់កម្មវិធី WIC សំរាប់ក្មេងតូចៗមានអាយុដល់ 5 ឆ្នាំ

### ការមកពិនិត្យមើលធ្មេញជាប្រចាំ និងការមើលថែទាំបន្តបើសិនជាត្រូវការ។

បើសិនជាត្រូវការកិច្ចបំរើបន្ថែមលើសុខភាព, ធ្មេញ ឬជម្ងឺវិបត្តិផ្លូវចិត្តយើងនឹងអាចជួយលោកអ្នកស្វែង រកកិច្ចការបំរើទាំងនោះអោយ។ ការវិនិច្ឆ័យរោគ និងការព្យាបាលនឹងបង់ថ្លៃអោយរហូតអោយតែ កូនលោកអ្នកនៅមាន Medi-Cal ។

ចំពោះមនុស្សដែលមានការជួយចេញថ្លៃព្យាបាលសុខភាពជាមួយនិង Medi-Cal, លោកអ្នកអាចឲ្យ កម្មវិធី CHDP បង់ថ្លៃមកពិនិត្យមើលរោគជាប្រចាំ ឬ លោកអ្នកបង់ថ្លៃមកពិនិត្យមើលប្រចាំ ហើយឲ្យគេឯកសងទៅនិងតម្លៃដែលលោកអ្នកត្រូវបង់នោះ។ មិនបាច់បង់ថ្លៃបន្ថែមពេលមកជួបវេជ្ជបណ្ឌិត (co-payment) ក្នុងពេលទទួលកិច្ចបំរើទាំងឡាយរបស់កម្មវិធី CHDP ឡើយ។

សូមយកមកជាមួយនៅកាត Medi-Cal និងបញ្ជីគត់សំគាល់នៃការចាក់ថ្នាំ។

## ពត៌មានៈ

ពត៌មានបន្ថែម ឬជំនួយក្នុងការដាក់ណាត់ជួបពេទ្យ និងយាន្តជំនិះ សូមទាក់ទងមកការិយាល័យ CHDP ក្នុងតំបន់របស់លោកអ្នករស់នៅ។ ចូររកមើលលេខទូរស័ព្ទរបស់ការិយាល័យនេះនៅក្នុងសៀវភៅទូរស័ព្ទនៅក្នុងផ្នែករដ្ឋាភិបាល។ ចូរមើលត្រង់ចំណងជើង *Child Health and Disability Prevention* (កម្មវិធីការពារសុខភាព & ភាពពិការរបស់ក្មេង) ឬ *Health Department* (មន្ទីរសុខាភិបាល)។

ឬក៏រកមើលការិយាល័យកម្មវិធី CHDP ក្នុងតំបន់តាមគេហទំព័រកុំព្យូទ័រ **www.dhs.ca.gov/chdp**

បើសិនជាលោកអ្នកត្រូវការការព្យាបាលជម្ងឺវិបត្តិផ្លូវចិត្ត សូមទូរស័ព្ទមកមន្ទីរព្យាបាលជម្ងឺវិបត្តិផ្លូវ ចិត្តនៅក្នុងស្រុក (ខោនធី) របស់លោកអ្នក។ មន្ទីរនេះអាចជួយផ្តល់ប្រាប់លោកអ្នកអំពីកិច្ចបំរើផ្សេងៗសំរាប់ឲ្យក្មេងតូចៗ និងក្មេងជំទង់ដែលទទួល Medi-Cal ពេញលេញដែលមានបញ្ហាខាងវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ។

លោក Arnold Schwarzenegger
អភិបាលរដ្ឋ, រដ្ឋកាលីហ្វ័រនីញ៉ា

(Cambodian, 1/04)

## Cambodian

### កម្មវិធីការពារសុខភាព & ភាពពិការរបស់ក្មេង (CHDP)

# ការមកពិនិត្យមើល សុខភាព & ធ្មេញជាប្រចាំ



### ដោយមិនគិតថ្លៃ ចំពោះទារក, ក្មេងតូចៗ និង ក្មេងជំទង់ដល់អាយុ 20 ឆ្នាំ

**ដោយពិនិត្យមើល Medi-Cal ពេញលេញ**

# ហេតុអ្វីបានជាចាំមកពិនិត្យមើលរោគជាប្រចាំ ?

ការមកពិនិត្យមើល**សុខភាព**អាចរកឃើញនូវបញ្ហាសុខភាព, បញ្ហាធ្មេញ ហើយ/ឬបញ្ហាវិបត្តិផ្លូវចិត្ត មុននឹងរោគទាំងអស់នោះក្លាយទៅជាបញ្ហាធ្ងន់ធ្ងរ។ ការចាក់ថ្នាំចាំបាច់បានចាក់រួចរាល់អស់ហើយ។ ជាឱកាសសាកសួរសំណួរ។ ការពិនិត្យមើលសុខភាពអាចតម្រូវអោយមាន នៅពេលគេតម្រូវ អោយធ្វើ ចំពោះការចិញ្ចឹមថែរក្សា, កីឡា ឬការទៅកំសាន្តនៅជំរុំ។ ទូទៅលោកអ្នកជាអាចទទួលការពិនិត្យរបស់កម្មវិធី CHDP នៅទីកន្លែងដែលលោកអ្នកទទួល ការព្យាបាលសុខភាពរបស់លោក អ្នក។

## ទារកនិងក្មេងតូចៗ
***ទើបកើតដល់អាយុ 3 ឆ្នាំ***

### សុខភាព និងការចាក់ថ្នាំទូទៅ

ទារកនិងក្មេងតូចៗត្រូវការការពិនិត្យមើលសុខភាពជាប្រចាំជាញឹកញាប់។ ទារកនិងក្មេងតូចៗត្រូវការចាក់ថ្នាំបានទាន់ពេលវេលា។



### តើពិនិត្យញឹកញាប់យ៉ាងណាដែរ ?

ពិនិត្យមើលសុខភាពម្តងក្នុងរយៈពេលមានអាយុ :

| | |
|---|---|
| ក្រោម 1 ខែ | 10-12 ខែ |
| 1-2 ខែ | 13-15 ខែ |
| 3-4 ខែ | 16-23 ខែ |
| 5-6 ខែ | 2 ឆ្នាំ |
| 7-9 ខែ | 3 ឆ្នាំ |

## ក្មេងមានអាយុចូលសាលារៀន
***អាយុ 4 ឆ្នាំ ដល់ 12 ឆ្នាំ***

### ការពិនិត្យសុខភាពសំរាប់ចូលសាលារៀន

ច្បាប់រដ្ឋបានតម្រូវឲ្យក្មេងចូលរៀនចាប់ពីមត្តេយ្យសាលា ឬថ្នាក់ទីមួយ ត្រូវមានការពិនិត្យមើលសុខ ភាព ហើយនិងការចាក់ថ្នាំជាប្រចាំបានទាន់ពេលវេលា។

ការពិនិត្យមើលសុខភាពអាចរកឃើញនូវបញ្ហាសុខភាពដែលជួយរារាំងកុំឲ្យកូនលោកអ្នករៀនសូត្រអន់ថយនៅសាលារៀន។



### តើពិនិត្យញឹកញាប់យ៉ាងណាដែរ ?

ពិនិត្យមើលសុខភាពម្តងក្នុងរយៈពេលមានអាយុ :

រវាងអាយុ 4-5 ឆ្នាំ
រវាងអាយុ 6-8 ឆ្នាំ
រវាងអាយុ 9-12 ឆ្នាំ

## ក្មេងជំទង់និងក្មេងពេញវ័យ
***អាយុ 13 ឆ្នាំ ដល់អាយុ 20***

### មកពិនិត្យមើលសុខភាពជាប្រចាំ

ក្មេងជំទង់ត្រូវការមកពិនិត្យមើលសុខភាពជាប្រចាំផងដែរ ! ពួកគេអាចមានសំណួរអំពីសុខភាពរបស់ខ្លួនគេ។ ពួកគេអាចសាកសួរអ្នកផ្តល់ការព្យាបាលបាន។



### តើពិនិត្យញឹកញាប់យ៉ាងណាដែរ ?

ពិនិត្យមើលសុខភាពម្តងក្នុងរយៈពេលមានអាយុ :

រវាងអាយុ 13-16 ឆ្នាំ
រវាងអាយុ 17-20 ឆ្នាំ

សូមសាកសួរវេជ្ជបណ្ឌិតរបស់លោកអ្នក ឬមន្ទីរសុខាភិបាលក្នុងតំបន់ចំពោះកិច្ចបំរើផ្សេងៗទៀតសំរាប់ក្មេងមានវ័យជំទង់នោះ។